# ជីវិតរស់នៅក្នុងលោកយើងនេះ គួរឲ្យសង្វេគណាស់។

## ៥

## ហេតុអ្វី បានជា ជីវិតរស់នៅសព្វថ្ងៃ ជាទុក្ខ តាមព្រះពុទ្ធសាសនា

*មានអ្នកក្រខ្លះ និយាយថា មកពីក្របានជាខ្លួនមានទុក្ខលំបាកបែបនេះ តែដល់ឃើញអ្នកខ្លះមានទ្រព្យសម្បត្តិក៏មានទុក្ខដែរ រហូតដល់ទៅសម្លាប់ខ្លួនក៏មាន ហើយអ្នកខ្លះធ្លាប់មាន បែរទៅជាក្រក៏មាន។ អ្នកខ្លះមានលុយ ហើយចាយមិនដាច់ ពីព្រោះមានជម្ងឺដើរទៅណាពុំរួច ។ ហេតុនេះហើយបានជា ក្នុងធម៌ព្រះពុទ្ធមានចែង ថា ជីវិតជាទុក្ខ ហើយទុក្ខមាន១២កង ដូចជា ការព្រាត់ប្រាសពីសត្វលោកដែលយើងស្រឡាញ់ជាទុក្ខ។ ការរួមរស់នៅជាមួយសត្វលោកដែលយើងស្អប់ជាទុក្ខ។ ការមិនបានសម្រេចដូចសេចក្ដីប្រាថ្នាជាទុក្ខ។ ចុះបើទុក្ខតែយ៉ាងនេះ ម្ដេចក៏នៅតែមានឃើញមនុស្សដែលសប្បាយរីករាយដែរ នៅតែមានមនុស្សឈឺ ខំមើលខ្លួនឲ្យជាដើម្បីនឹងរស់តទៅទៀត ដោយមិនចង់ស្លាប់? ចម្លើយគឺថា អ្វីៗក្នុងលោកនេះសុទ្ធតែមិនទៀង សុទ្ធតែមានគូនឹងគ្នាជានិច្ច គឺថា បើមានពេលមានទុក្ខ ក៏មានពេលមានសេចក្ដីសុខសប្បាយដែរ។ បើមានរដូវត្រជាក់ ក៏មានរដូវក្ដៅដែរ ។ បើពេលខ្លះមានចិត្តបុណ្យ ក៏មានពេលខ្លះមានចិត្តបាបដែរ ។ល។ ធម៌ មិនទៀងនេះ ជាច្បាប់ធម្មជាតិ។ យើងមិនអាចកែច្បាប់ធម្មជាតិឲ្យមកតាមចិត្តយើងបានឡើយ។ ដើម្បីបានសេចក្ដីសុខ ទាល់តែយើងរៀនរស់នៅ*

ឲ្យស្របតាមច្បាប់ធម្មជាតិ  ក៏ដូចសព្វថ្ងៃនេះ យើងត្រូវរស់នៅឲ្យស្របតាមច្បាប់រដ្ឋនោះដែរ ។ ប្រសិនបើជាយើងពុំអាចកែច្បាប់ធម្មជាតិបាន តែយើងក៏ត្រូវរកមធ្យោបាយដើម្បីការពារខ្លួនយើងដែរ  ដូចជា ភ្លៀងខ្យល់ជាបាតុភូតនៃច្បាប់ធម្មជាតិ យើងមិនអាចទប់ទល់នឹងបាតុភូតនោះបានទេ តែយើងអាចការពារខ្លួនយើងដោយបង្កើតសំលៀកបំពាក់ដូចជាអាវភ្លៀង  ឆ័ត្រ សង់ផ្ទះមានដំបូល ដើម្បីកុំឲ្យទទឹកនៅពេលភ្លៀង។

រួមសេចក្តីទៅ  ដើម្បីបានសេចក្តីសុខ យើងត្រូវស្គាល់ច្បាប់ធម្មជាតិ ដើម្បីនឹងរស់នៅទៅតាមច្បាប់នោះ ។ ធម៌ព្រះពុទ្ធ  មានប្រយោជន៍ដល់យើងពីព្រោះធម៌ព្រះអង្គ ស្របនឹងច្បាប់ធម្មជាតិ ។ ព្រះអង្គដោះស្រាយបញ្ហាទាំងពួងដោយទុកច្បាប់ធម្មជាតិជាល័ក្ខខ័ណ្ឌ។ ក្នុងធម៌ព្រះអង្គ មានពាក្យ បាលី **អនិច្ចំ**  ប្រែថា « មិនទៀង »  ហើយធម៌ទាំងអស់របស់ព្រះអង្គ គឺចេញពីធម៌ អនិច្ចំ នេះ ។  ដូចយើងដឹងស្រាប់ហើយ  ធម៌ត្រៃលក្ខណ៍ គឺ **អនិច្ចំ  ទុក្ខំ  អនត្តា** ៖ [ធម៌ទាំងឡាយមិនទៀង] [ធម៌ណាមិនទៀងជាទុក្ខ] ហើយ [ ធម៌ណាមិនទៀង និងជាទុក្ខ  មិនមែនជាយើង  មិនមែនជារបស់យើងទេ ] ។ ព្រះអង្គត្រាស់ដឹង មិនមែនដោយសារធម៌ **អនិច្ចំ** នេះប៉ុណ្ណោះទេ  ពីព្រោះធម៌នេះគ្រាន់តែជា **ហេតុ** ដែលនាំឲ្យកើត **ទុក្ខ** ។ ធម៌ដែលសំខាន់ គឺ ធម៌ដែលនាំទៅរកការ**រំលត់ទុក្ខ** ។ ដូចជាគ្រូពេទ្យ មើលជម្ងឺ  បើគ្រាន់តែប្រាប់ហេតុដែលនាំឲ្យឈឺពោះ ហើយមិនឲ្យថ្នាំសម្រាប់បំបាត់ជម្ងឺនោះទេ  ក៏មិនគ្រប់គ្រាន់ដែរ ។  ការពិចារណារបស់ព្រះអង្គ គឺ នៅលើភពយើងនេះ មានច្បាប់ធម្មជាតិ  **អនិច្ចំ**  ហើយ អនិច្ចំ ជាទុក្ខ។ ដោយយើងកែច្បាប់ធម្មជាតិមិនបាន ដូច្នេះ ដើម្បីផុតទុក្ខ ទាល់តែយើងកុំកើតនៅលើភពទាំងបី (កាមភព រូបភព  និង អរូបភព) ។ នៅ កាមភព មាន មនុស្ស ទេវតា និង (តិរច្ឆាន

អសុរកាយ ប្រេត នរក )។ ដូច្នេះ ធម៌ដែលព្រះអង្គរក គឺ ធម៌ដែលនាំទៅរកការ **មិនកើតតទៅទៀត** ។ ខ្ញុំរៀបរាប់ខាងលើនេះបាន ដោយសារខ្ញុំឃើញ លទ្ធផល គឺធម៌ដែលព្រះពុទ្ធបានរកឃើញរួចហើយ តែបើពុំទាន់បានឃើញធម៌ព្រះពុទ្ធរកឃើញទេនោះ ខ្ញុំក៏ពុំហ៊ានប៉ាយប៉ាប់ពីការពិចារណាជាដំបូង របស់ព្រះអង្គដែរ ។ ពីព្រោះក្នុងការស្រាវជ្រាវ (recherche) មុនដំបូង គេដាក់ជា សម្មតិកម្ម (hypothèse) សិន ហើយបន្ទាប់មក បាន គេខំរាវរកទៅតាមលំនាំ នៃសម្មតិកម្មនោះ ។ ដូចជាក្នុងការស្រាវជ្រាវនេះ សម្មតិកម្ម គឺ « បើមានធម៌ដែលនាំទៅរកការ **កើត** ក៏ត្រូវមានធម៌ដែលនាំទៅរកការ **មិនកើត**ដែរ »។ ដោយ សម័យកាលព្រះពុទ្ធ **គោតម** ពុំទាន់មានអ្នកសិក្សាខាងសាសនាណាមួយនឹកឃើញនូវសម្មតិកម្ម (hypothèse) ខាងលើនេះនៅឡើយ ហេតុនេះហើយបានជាថាព្រះអង្គបានរកឃើញធម៌ **និព្វាន**នេះ ដោយព្រះអង្គឯង ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។ ឧបមាថា មានលោកអ្នកខ្លះដែលកំពុងតែអានអត្ថបទនេះ សួរខ្ញុំថា ៖ ឥឡូវខ្ញុំយល់ហើយថា ការកើតនៅលើពិភពលោកយើងនេះជាទុក្ខ ហើយមានតែបានសម្រេចព្រះនិព្វានទេ ទើបរួចចាកទុក្ខបាន។ តើត្រូវធ្វើរបៀបណា ទើបបានសម្រេច ព្រះនិព្វានបាន ?

ខ្ញុំសូមស្វាគមន៍នូវសំណួរនេះ ពីព្រោះដោយហេតុសំណួរនេះ និងដើម្បីនឹងរកចម្លើយនៃសំណួរនេះហើយ បានជាព្រះពុទ្ធនៃយើងទ្រង់ចេញទៅបួស ។ ធម៌របស់ព្រះអង្គទាំងឡាយ ទៅរកទិសដៅតែមួយ គឺ៖ **សម្រេច ព្រះនិព្វាន** គឺ ផុតចាកទុក្ខ ។ យើងថាព្រះអង្គត្រាស់ដឹង គឺត្រង់ព្រះអង្គរកឃើញនូវ « ធម៌នាំទៅនិព្វាន » ព្រោះពាក្យនិព្វានមានន័យ លុះត្រាតែមានធម៌ដែលនាំយើងទៅដល់និព្វាននោះ បើមិនដូច្នោះទេ គឺគ្រាន់តែជាពាក្យធម្មតាប៉ុណ្ណោះ មិនមានអ្វីជាអស្ចារ្យទេ ។

« ធម៌ នាំទៅនិព្វាន » ដែលព្រះពុទ្ធបានត្រាស់គឺ **ចតុរារិយសច្ច** (អរិយសច្ច៤)

ដែលនៅក្នុងនោះ មាន **អដ្ឋង្គិកមគ្គ** ជា **គោល**នៃផ្លូវសម្រាប់ **បដិបត្តិតាម** ដើម្បីនឹងបានសម្រេចព្រះនិព្វាន ។

ព្រះពុទ្ធ បន្ទាប់ពីបានត្រាស់ដឹងធម៌នេះហើយ ព្រះអង្គមិនលាក់ទុកធម៌នេះសម្រាប់តែមួយព្រះអង្គឯង ឬ សម្រាប់ តែព្រះញាតិវង្សទេ ។ ព្រះអង្គខំរកមធ្យោបាយយ៉ាងណា ដើម្បីផ្សព្វផ្សាយធម៌នេះដល់សត្វលោកទាំងមូល ដើម្បីឲ្យបានរួចចាកទុក្ខដូចព្រះអង្គដែរ ។ ដោយសត្វលោកមានបញ្ញាមិនដូចគ្នា មានឧបនិស្ស័យមិនដូចគ្នា ដើម្បីឲ្យបានយល់គ្រប់គ្នា កុំឲ្យមានការយល់ច្រឡំក្នុងការ **បដិបត្តិ** ព្រះអង្គបានវែកញែក លំអិត ធម៌ព្រះអង្គ **ជាហេតុ ជាផល** សម្រាប់យើងយកទៅពិចារណា ។

នៅក្នុងព្រះពុទ្ធសាសនាការពិចារណា សំខាន់ណាស់ ព្រះអង្គមិនចង់ឲ្យយើងជឿនូវធម៌ព្រះអង្គដោយល្ងិតល្ងង់នោះទេ ព្រះអង្គចង់ឲ្យយើងជឿដោយបានប្រើបញ្ញា ពីព្រោះធម៌ព្រះអង្គសុទ្ធតែពឹងផ្អែកទៅលើហេតុផលទាំងអស់ ហេតុនេះហើយបានជា មានពាក្យថា **ធម៌** គឺ **ធម្មជាតិ** ។ ច្បាប់ធម្មជាតិ សុទ្ធតែមានហេតុផល តែជួនកាលគេរកហេតុពិតនោះពុំទាន់ឃើញ ដូចជាជម្ងឺអាលសៃម៉ើរ (Alzheimer) ជាដើម ។ តែបើមេឃភ្លៀងវិញ គេអាចថា មេឃភ្លៀង មកពីពពក ហើយ ពពក មកពីចំហាយទឹក ហើយចំហាយទឹក មកពីធាតុអាកាសក្តៅ ...។ល។

ដោយហេតុចង់ឲ្យបានយល់គ្រប់គ្នានេះហើយ បានជាធម៌របស់ព្រះអង្គមានទៅដល់ ៨៤០០០ ធម្មខន្ធ ។ មិនត្រឹមតែប៉ុណ្ណោះ ក្នុងការ បដិបត្តិ ព្រះអង្គបានចែកធម៌ជាថ្នាក់ៗ ដូចជា នៅក្នុង **អដ្ឋង្គិកមគ្គ** មានចែកជាបីថ្នាក់ គឺ **សីល សមាធិ បញ្ញា** ។ ធម៌ទាំងបីនេះជួយគ្នាទៅវិញទៅមក ដូច្នេះសុទ្ធតែមានប្រយោជន៍ទាំងអស់ពីព្រោះមនុស្សយើងម្នាក់ៗ មាន កាយ និង ចិត្ត ឬ ខន្ធ៥ ហើយ កាយនិងចិត្ត ត្រូវការគ្នាទៅវិញទៅមកជានិច្ច ។ បើជើងឈឺ ហើយចិត្តចង់ទៅវត្ត តើទៅវត្តកើតទេ ? ឆ្លើយថាទៅមិន

*កើតទេ ។ ដូចអ្នកដក់បារីខ្លះ ដោយបញ្ញា បានយល់ច្បាស់ហើយថា ដក់បារីនាំឲ្យមាន ជម្ងឺមហារីកសួត តែនៅតែដក់បារី ផឹកស្រាដដែល ។ ឧទាហរណ៍នេះបង្ហាញថាគ្រាន់ តែយល់ដោយបញ្ញាមិនទាន់គ្រប់គ្រាន់ទេ ត្រូវមានការបដិបត្តិ ដោយអប់រំចិត្តិថែមទៀត ដូចជាការកាន់សីល ធ្វើសមាធិជាដើម ។ មុននឹងបញ្ចប់ ខ្ញុំសូមជូនអត្ថន័យពាក្យខ្លះ តាមដែលខ្ញុំ បានឮ បានយល់ ៖*

**ទុក្ខ** : *ភាព (ភាវៈ) ដែលទ្រាំពុំបាន ដោយកាយ ឬ ដោយចិត្ត ឧបមា អ្នកខ្លះទ្រាំបាន តែត្រឹម ជាតុអាកាស -5° (ក្រោម ៥ អង្សា) ហើយ អ្នកខ្លះទ្រាំបានដល់ -10° (ក្រោម ១០ អង្សា) ។ ទុក្ខដោយ កាយត្រជាក់ ចិត្តខំទ្រាំមិនត្អូញត្អែរ ។*

*ចំពោះពាក្យ នរក សួគ៌ ឬ និព្វាន ដោយយើងមិនទាន់ទៅដល់ យើងស្គាល់តែឋាន* **កណ្តាល** *ដូច្នេះមានតែការប្រៀបធៀបនឹងស្ថានដែលយើងរស់នៅសព្វថ្ងៃនេះប៉ុណ្ណោះ ។*

**និព្វាន** : *ភាព (ភាវៈ) សុខ ឥតមានទុក្ខ (សុខក្នុងន័យ នត្ថិ សន្តិ បរំ សុខំ )*

**នរក** : *ភាព (ភាវៈ) ទុក្ខ ឥតមានសុខ*

**ឋានសួគ៌** : *ឋានដែល មានសុខ ច្រើនជាងទុក្ខ*

**ឋានកណ្តាល** *យើង គឺ មានសុខ និង ទុក្ខ ប្រហាក់ប្រហែលគ្នា ។*